**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**
**លេខ:** ៣៤៩ **គ.ជ.ប**

# គោលការណ៍
## សម្រាប់បោះពុម្ព និងផ្សព្វផ្សាយអត្ថបទឃោសនាបោះឆ្នោត របស់គណបក្សនយោបាយក្នុងព្រឹត្តិបត្រគោលនយោបាយគណបក្ស សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ អាណត្តិទី៤ ឆ្នាំ២០២៤

- យោងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- យោងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ
- យោងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ
- យោងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) នឹងរៀបចំបោះពុម្ពព្រឹត្តិបត្រគោលនយោបាយគណបក្សចំនួន ២ (ពីរ) លេខ ក្នុងពេលឃោសនាបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ អាណត្តិទី៤ ឆ្នាំ២០២៤។

ដើម្បីឱ្យការបោះពុម្ពព្រឹត្តិបត្រនេះប្រព្រឹត្តទៅតាមគោលការណ៍ស្មើភាព គណបក្សនយោបាយដែលបានចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត មានសិទ្ធិផ្តល់អត្ថបទស្តីពីគោលនយោបាយរបស់គណបក្សខ្លួនមក គ.ជ.ប ដើម្បីធ្វើការបោះពុម្ព និងផ្សព្វផ្សាយជាសាធារណៈដោយឥតគិតថ្លៃ។

គ.ជ.ប សម្រេចចេញនូវគោលការណ៍ស្តីពីការបោះពុម្ព និងផ្សព្វផ្សាយដូចខាងក្រោម៖

### ១. លក្ខខណ្ឌនៃការបោះពុម្ព

១.១ អត្ថបទគោលនយោបាយរបស់គណបក្សត្រូវមានទំហំ A4 (21cm x 29.7cm)

Page Setup: - Top : 1.5 cm
- Bottom : 1.5 cm
- Left : 2.5 cm
- Right : 1.5 cm

១.២ គណបក្សនយោបាយនីមួយៗ ត្រូវផ្តល់នូវអត្ថបទគោលនយោបាយរបស់ខ្លួនចំនួន ៣ (បី) ទំព័រ A4 ក្នុង ១ (មួយ) លេខ។

១.៣ គណបក្សនយោបាយត្រូវរចនាអត្ថបទឃោសនាបោះឆ្នោតឱ្យរួចរាល់មុននឹងផ្តល់មកឱ្យ គ.ជ.ប។

១.៤ គណបក្សនយោបាយអាចផ្តល់នូវខ្លឹមសារឃោសនាបោះឆ្នោតរបស់ខ្លួនជាអត្ថបទក៏បាន ឬជារូបភាព ស ខ្មៅ ស្តីពីសកម្មភាពរបស់គណបក្សខ្លួនក៏បាន។

១.៥ គណបក្សនយោបាយអាចផ្តល់ខ្លឹមសារនៃការឃោសនានេះជាឯកសារក្រដាស (Hard Copy) និងជាឯកសារក្នុងកុំព្យូទ័រ (Soft Copy)។

១.៦ គណបក្សនយោបាយនីមួយៗត្រូវផ្តល់អត្ថបទឃោសនាមក គ.ជ.ប សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ អាណត្តិទី៤ ឆ្នាំ២០២៤ រហូតដល់ ១៤ (ដប់បួន) ថ្ងៃ យ៉ាងតិចមុនថ្ងៃចាប់ផ្តើមឃោសនាបោះឆ្នោត។

១.៧ លេខរៀងទំព័រចុះផ្សាយក្នុងព្រឹត្តិបត្រ ត្រូវធ្វើការចាប់ឆ្នោតដោយតំណាងគណបក្សនយោបាយ។

## ២. ការបែងចែក និងការផ្សព្វផ្សាយ

២.១ គណបក្សនយោបាយត្រូវចាត់តំណាងរបស់ខ្លួនមកទទួលយកព្រឹត្តិបត្រគោលនយោបាយនៅ គ.ជ.ប ដើម្បីផ្សព្វផ្សាយ។

២.២ គ.ជ.ប ត្រូវធ្វើការបែងចែក និងផ្សព្វផ្សាយដល់ស្ថាប័ននីតិប្បញ្ញត្តិ ស្ថាប័ននីតិប្រតិបត្តិ អង្គការសង្កេតការណ៍បោះឆ្នោត ស្ថានទូត និងអង្គភាពសារព័ត៌មានដោយឥតគិតថ្លៃ។

## ៣. គោលការណ៍ច្បាប់

៣.១ ខ្លឹមសារអត្ថបទឃោសនារបស់គណបក្សនយោបាយ ត្រូវគោរពគោលការណ៍ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សា-ខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ។

៣.២ ក្នុងករណី គ.ជ.ប ពិនិត្យឃើញខ្លឹមសារនៃអត្ថបទឃោសនាប្រាសចាកពីគោលការណ៍ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង

ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ គ.ជ.ប មានសិទ្ធិស្នើឱ្យធ្វើការកែតម្រូវមុននឹងបោះពុម្ពផ្សាយ។

៣.៣ ក្នុងករណីគណបក្សនយោបាយមិនអនុវត្តតាមការស្នើសុំឱ្យកែតម្រូវ គ.ជ.ប មិនចុះផ្សាយនូវអត្ថបទឃោសនានោះឡើយ។

៣.៤ គ.ជ.ប មិនទទួលខុសត្រូវចំពោះគណបក្សនយោបាយដែលមិនគោរពតាមចំណុច ១.៥ នៃគោលការណ៍នេះ។

ថ្ងៃព្រហស្បតិ៍ ៤រោច ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៤

**ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធាន**

**ប្រាជ្ញ ចន្ទ**